**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង

## ស្តីពី

## លទ្ធផលនៃសិក្ខាសាលាស្តីពីការពង្រឹងសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈ

នាថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧ នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានការរៀបចំសិក្ខាសាលាស្តីពីការពង្រឹងសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈ ដោយមានការចូលរួមពីថ្នាក់ដឹកនាំសហភាពសហជីព សហព័ន្ធសហជីព ដែលជាតំណាងកម្មករនិយោជិត តំណាងនិយោជក និងតំណាងរាជរដ្ឋាភិបាល ប្រមាណជាង៣០០នាក់។ គោលបំណងនៃសិក្ខាសាលានេះ គឺដើម្បីបន្តពន្យល់បន្ថែមពីដំណើរការនៃការចុះបញ្ជីសហជីព និងសមាគមនិយោជក ជាពិសេសឆ្លើយតបនូវចម្ងល់នានារបស់ភាគីពាក់ព័ន្ធក្នុងការអនុវត្តច្បាប់ស្តីពីសហជីព ច្បាប់ស្តីពីការងារ និងលិខិតបទដ្ឋានពាក់ព័ន្ធនានា។ ក្រោយពីការពិភាក្សាយ៉ាងផុលផុស អង្គសិក្ខាសាលាបានទទួលនូវលទ្ធផល ដូចខាងក្រោម៖

១-បានបំភ្លឺនូវចម្ងល់នានារបស់ភាគីពាក់ព័ន្ធក្នុងការអនុវត្តច្បាប់ស្តីពីសហជីព និងច្បាប់ស្តីពីការងារ ជាពិសេសនីតិវិធីនៃការចុះបញ្ជី និងការរក្សាបញ្ជិកា។

២-បានយល់ដឹងច្បាស់ពីនីតិវិធីនៃការកំណត់កូរ៉ុមប្រជុំ ដើម្បីសម្រេចក្នុងការកែប្រែលក្ខន្តិកៈ រៀបចំមហាសន្និបាត និងធ្វើកូដកម្ម។

៣-បានយល់ដឹងពីគោលការណ៍នៃការស្នើសុំភាពជាតំណាងបំផុតរបស់សហជីពក្នុងសហគ្រាស គ្រឹះស្ថាន និងនីតិវិធីបង្កើតប្រតិភូចរចាសម្រាប់ដោះស្រាយវិវាទការងាររួមនៅតាមសហគ្រាស គ្រឹះស្ថានដែលមិនទាន់មានសហជីព ឬមានសហជីពប៉ុន្តែមិនទាន់មានភាពជាតំណាងបំផុត។

៤-បានយល់ច្បាស់ពីយន្តការបណ្តឹងឧបាស្រ័យមករដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅពេលដែលមានការមិនពេញចិត្តនឹងចំណាត់ការណាមួយរបស់មន្ត្រី ដែលទទួលបានប្រតិភូកម្មពាក់ព័ន្ធនឹងការចុះបញ្ជី និងរក្សាបញ្ជិកា។

៥-បានឯកភាពជាគោលការណ៍ក្នុងការកំណត់និយមន័យកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា (មានថិរវេលាកំណត់)។

៦-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនឹងចេញនូវសេចក្តីណែនាំដើម្បីអនុវត្តចំណុចខាងលើនេះ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជន កម្មករនិយោជិត និយោជក អង្គការវិជ្ជាជីវៈគ្រប់ជាន់ថ្នាក់ អង្គការជាតិ និងអន្តរជាតិ មេត្តាជ្រាបជាព័ត៌មានតាមការគួរ។

*រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧*